# *ការអបអរសម្រាប់* ក្រុមទាំងពីរ

ដោយ អាស្លី ស្លាក
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅក្នុងប្រទេសកូរ៉េ ខាងត្បូង ។*

ជេនី បានញាំមីមួយមាត់ចុងក្រោយរបស់នាង ។ *ឆ្ងាញ់* ឆ្ងាញ់ណាស់ !

« តោះទៅលេង Yut Nori ! » លោកតា ជីហូ មានប្រសាសន៍ ។

ដល់វេលាលេងនេះទៀតហើយ ! គ្រួសាររបស់នាងបានប្រារព្ធពិធីបុណ្យថ្លែងអំណរគុណ *Chuseok* ប្រទេសកូរ៉េ ។ ថ្ងៃនេះ គ្រួសាររបស់ជេនី បានជួបជុំគ្នាបរិភោគអាហារជាច្រើន ហើយលេង Yut Nori ជាមួយគ្នា ។ Yut Nori ជាល្បែងកំសាន្តដែលជេនីចូលចិត្ត ។

មនុស្សគ្រប់គ្នាអង្គុយជារង្វង់មួយនៅលើកម្រាលឥដ្ឋ ។ ជេនី បានសម្លឹងមើលជុំវិញខ្លួន ។ តើនាងចង់ចូលក្រុមមួយណា ? នាងបានខិតទៅអង្គុយក្បែរលោកតា ជីហូ ។ នាងបាននិយាយថា « ក្មួយចង់នៅក្នុងក្រុមជាមួយលោកតា ! » ។ « យើងនឹងក្លាយជាអ្នកឈ្នះខ្លាំងជាងគេ ! »

លោកតា ជីហូ បានសើច ។ « ដោយសារមានឯងនៅក្នុងក្រុម យើងប្រាកដជាមានឱកាសឈ្នះ ! »

ម្ដាយរបស់ជេនី បានរៀបចំក្ដារសម្រាប់លេងល្បែងនោះនៅចំកណ្ដាលរង្វង់ ។ ជេនី បានជួយម្ដាយនាងរៀបចំផ្នែកផ្សេងៗទាំងនោះ ។ ពួកគេបានហុចឈើបួនកំណាត់ទៅឲ្យក្រុមដែលដល់វេនមុន ។

បងប្អូនជីដូនមួយរបស់ជេនី ឈ្មោះអាណា បានដល់វេនមុន ។ នាងបានបោះឈើទៅលើ ។ របៀបដែលឈើជ្រុះដល់ដី បង្ហាញពីចំនួនដែលក្រុមអាចដើរបាននៅលើក្ដារប្រកួតនោះ ។ ឈើទាំង ៤ កំណាត់ ជ្រុះផ្កាប់មុខចុះមានន័យថា អាណាទទួលបាន Yut ! នាងអាចរំកិលបំណែករបស់ក្រុមនាងទៅមុខបួនជំហាន *ហើយ* អាចបោះបន្ថែមម្ដងទៀត ។

ប៉ុន្តែ អាណាមិនបាននៅក្នុងក្រុមរបស់ជេនីទេ ។

ជេនី បានឱបដៃរបស់នាង ហើយចងចិញ្ចើម ។ នាងបានខ្សឹបប្រាប់លោកតា ជីហូ ថា ៖ « ខ្ញុំសង្ឃឹមថានាងនឹងបោះមិនបានល្អទេ » ។

« ចូរសង្ឃឹមឡើយ ! » លោកតា ជីហូ មានប្រសាសន៍ ។ « ទើបតែចាប់ផ្ដើមលេងទេ »។ គាត់បានញញឹមលើកទឹកចិត្តនាង ។

*ជេនី ជ្រួញចិញ្ចើម ។ នាងមិនចង់ឲ្យក្រុមផ្សេងឈ្នះទេ !*



ក្រោយពីដល់វេនរបស់អាណា ជាលើកទី២ ក្រុមរបស់ជេនី បានបោះឈើម្ដង ។ ប៉ុន្តែ ពួកគេមិនអាចរំកិលបំណែករបស់ពួកគេបានឆ្ងាយដូចក្រុមរបស់អាណាទេ ។

នៅពេលដល់វេនគ្រប់គ្នារួចហើយ សមាជិកគ្រួសាររបស់ជេនី បានអបអរហើយសើចសប្បាយ ។ ជេនី បានមើលបំណែកផ្លាស់ទីជុំវិញក្ដារ ។ គ្រប់គ្នាសប្បាយរីករាយ ។

លើកលែងតែជេនី ប៉ុណ្ណោះ ។ ក្រុមរបស់នាងនៅតែចាញ់ ។

ទីបំផុត វាគឺជាវេនរបស់ជេនី ។ នាងបានបោះឈើទៅលើ ប៉ុន្តែមានតែឈើមួយប៉ុណ្ណោះដែលធ្លាក់មកផ្កាប់មុខចុះ ។ បំណែករបស់ក្រុមនាងបានឆ្ពោះទៅមុខតែមួយជំហានប៉ុណ្ណោះ ។

ជេនី បានឱបដៃរបស់នាង ។ នាងស្រែកថា «ខ្ញុំឈប់លេងហើយ ! » ។ « ខ្ញុំចង់ឲ្យយើងឈ្នះ » ។

ភ្លាមនោះ គ្រប់គ្នាបានស្ងប់ស្ងាត់ ។ ពេលនាងងើបមុខឡើង គ្រួសាររបស់នាងកំពុងសម្លឹងមើលនាង ។ ពួកគេហាក់ដូចជាភ្ញាក់ផ្អើលដែលនាងខឹងខ្លាំងដូច្នេះ ។

មុខរបស់ជេនី ឡើងក្រហម ។ នាងស្ដាយដែលនាងមិនសប្បាយចិត្ត សម្រាប់គ្រួសាររបស់នាង ។ ជាធម្មតា នាងមិនខឹងបែបនេះទេ ។ នាងក្រោកឈរឡើងដើម្បីដើរចេញពីរង្វង់ ។

លោកតា ជីហូ ចាប់ដៃនាង ។ លោកតាបាននិយាយថា « ក្មួយមិនចាំបាច់ចេញទេ » ។ « ការឈ្នះមិនមែនជាទីបញ្ចប់នោះទេ » ។ គ្រាន់តែព្យាយាមលេងឲ្យសប្បាយទៅ » ។

« ចាស » ។ ជេនី អង្គុយចុះវិញ ។ នាងចង់សប្បាយដូចគ្រប់គ្នាដែរ ។ នាងបានដកដង្ហើមធំ ហើយបានមើលបងប្អូនជីដូនមួយរបស់នាង ឈ្មោះបេន បោះឈើ ។

« ធ្វើឲ្យបានល្អណា បេន ! » លោកតា ជីហូ មានប្រសាសន៍ ។ ស្ដាប់ទៅគាត់សប្បាយណាស់ ។

ជេនី បានបើកភ្នែកធំៗសម្លឹងលោកតា ជីហូ ។ គាត់កំពុងអបអរសម្រាប់ក្រុមផ្សេងទៀត ! ប្រហែលនេះជាមូលហេតុដែលគាត់បានសប្បាយរីករាយយ៉ាងខ្លាំង ។

នៅពេលដល់វេនបន្ទាប់បានចាប់ផ្ដើម ជេនីបានសម្រេចចិត្តអបអរឲ្យគ្រប់គ្នានៅក្នុងក្រុម*ទាំងពីរ* ។ លោកតា ជីហូ និយាយត្រូវ ។ ការឈ្នះមិនមែនជាទីបញ្ចប់ទេ ។ ព្រះយេស៊ូវអាចជួយនាងឲ្យរីករាយសម្រាប់សមាជិកគ្រួសាររបស់នាង ទោះបីជានាងចាញ់ក៏ដោយ ។

ពេលវេនរបស់អាណាម្ដងទៀត ជេនីបានញញឹមដាក់នាង ។ « សូមសំណាងល្អ ! ឯងអាចធ្វើបាន ! » ។

អាណាអង្គុយទល់មុខនោះ ហើយញញឹមដាក់វិញ ។ ជេនី មានអារម្មណ៍កក់ក្ដៅក្នុងចិត្ត ។ តែមួយភ្លែតសោះ នាងសប្បាយជាងមុនទៅហើយ ! ●

« អ្វីៗជាច្រើននៅក្នុងជីវិតនេះ គឺពឹងផ្អែកទៅលើអាកប្បកិរិយារបស់យើង ។ របៀបដែលយើងជ្រើសរើសដើម្បីមើល និងឆ្លើយតបចំពោះអ្នកដទៃ ធ្វើឲ្យមានភាពខុសប្លែកគ្នាទាំងស្រុង » ។

ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) « Living the Abundant Life » *Liahona,* ខែ មករា ឆ្នាំ ២០១២ ទំព័រ ៤ ។